ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រួមគ្នាដើម្បីសហគមន៍កាន់តែរឹងមាំ

# គោលការណ៍ឯកភាពរួមរវាង
# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS)
# និង
# អង្គការខាណា (KHANA)
# លើការងារបង្ការ-ថែទាំព្យាបាលបន្តជំងឺអេដស៍
# ក្នុងចំណោមអ្នកចាក់គ្រឿងញៀន (PWID) និងអ្នកប្រើគ្រឿងញៀនប្រភេទផ្សេងទៀត (PWUD)

១. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ និងអង្គការ KHANA បានកត់សំគាល់ឃើញថា មានការកើនឡើងបន្តិចនូវអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុមចាក់គ្រឿងញៀន (PWID) និងចំពោះអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទផ្សេងទៀត (PWUD) រយៈពេលប្រាំឆ្នាំចុងក្រោយ (ផ្អែកលើការអង្កេត IBBS របស់ NCHADS និងដៃគូអភិវឌ្ឍន៍ឆ្នាំ២០១១)។ អត្រានៃការធ្វើតេស្តរកមេរោគអេដស៍និងការពិនិត្យជំងឺកាមរោគក្នុងចំណោម PWID និង PWUD មានកំរិតទាបនៅឡើយ។

២. ដើម្បីសំរេចអោយបានទិសដៅរបស់ក្រសួងសុខាភិបាល ក្នុងការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅឆ្នាំ២០២០ NCHADS, KHANA និងដៃគូអភិវឌ្ឍន៍នានា បានឯកភាពលើការបង្កើនការទទួលបានសេវាបង្ការ-ថែទាំ និងព្យាបាលជំងឺអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់នៃការឆ្លងមេរោគអេដស៍ (MARP) ជាពិសេសផ្តោតលើក្រុមប្រើប្រាស់គ្រឿងញៀនដោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធវិធីជំរុញក្លាំងក្លាការបង្ការថែទាំ និងព្យាបាលបន្តនៃគំនិតផ្តួចផ្តើម “កម្ពុជា៣.០” ដែលបានអនុម័តដោយក្រសួងសុខាភិបាលនៅ ខែកញ្ញា ឆ្នាំ២០១២។ NCHADS និងKHANA បានយល់ព្រមលើគោលការណ៍នៃការស្រាវជ្រាវរកអោយឃើញ នូវករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោម MARP ជាពិសេស PWID និង PWUD និងដៃគូរបស់ពួកគេ (Partners) ដើម្បីទទួលបានភ្លាមៗ ឬដោយឆាប់រហ័សនូវការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ (Test and Treat)។

៣. NCHADS, KHANA និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាបានឯកភាពលើការពង្រឹងបណ្តាញរបស់ PWID និង PWUD ដើម្បីអោយពួកគេបានចូលរួមក្នុងការរៀបចំ ឬពិនិត្យឡើងវិញនូវគោលនយោបាយ សេចក្តីណែនាំ និយាមបែបបទដែលពាក់ព័ន្ធនឹងការផ្តល់សេវា HIV ដល់ពួកគេ។

៤. ដើម្បីសំរេចបាននូវគោលដៅនៃគំនិតផ្តួចផ្តើម "កម្ពុជា ៣.០" ក្នុងការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅឆ្នាំ ២០២០ ជាពិសេសក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន NCHADS និង KHANA បានឯកភាពលើភារកិច្ចទទួលខុសត្រូវលើការងារដូចខាងក្រោម ៖

## ៤.១.ភារកិច្ចទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ រួមមាន៖

**៤.១.១.** ចូលរួមនិងដឹកនាំដោយសហការជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ រៀបចំគោលនយោបាយ ផែនការយុទ្ធវិធី-សេចក្តីណែនាំ-និយាមបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងការបង្ការថែទាំ ព្យាបាលបន្តជំងឺអេដស៍ក្នុងចំណោមក្រុមប្រើប្រាស់គ្រឿងញៀន។

**៤.១.២.** ផ្គត់ផ្គង់ប្រតិករ និងសំភារៈធ្វើតេស្តរកមេរោគអេដស៍ដល់បណ្តាញរបស់ KHANA ដែលបានបណ្តុះបណ្តាលពីជំនាញផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមនៅតាមសហគមន៍ (C/PITC)។

**៤.១.៣.** បណ្តុះបណ្តាលបុគ្គលិករបស់ KHANA និងអ្នកអប់រំផ្ទាល់ (Outreach Worker) អំពីការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដោយអនុវត្តតាមនិយាមបែបបទនៃការអនុវត្តន៍ HTC ដែលបានអនុម័តដោយក្រសួងសុខាភិបាលនៅខែកញ្ញាឆ្នាំ២០១២។

**៤.១.៤.** ផ្តល់ជំនាញបច្ចេកទេសលើការត្រួតពិនិត្យគុណភាពនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដល់បណ្តាញរបស់ KHANA ដែលបានអនុញ្ញាតិអោយអនុវត្ត C/PITC លើក្រុមប្រើប្រាស់គ្រឿងញៀន។

**៤.១.៥.** សហការជាមួយគ្រប់សេវាថែទាំ និងព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ (Pre-ART/ART) និងបណ្តាញរបស់ KHANA ដោយធានាថាគ្រប់ PWID និង PWUD (១០០ភាគរយ) ដែលមានលទ្ធផលតេស្តរកមេរោគអេដស៍វិជ្ជមាន ត្រូវទទួលបានភ្លាមៗនូវការព្យាបាលដោយឱសថ ARV។

**៤.១.៦.** ផ្សព្វផ្សាយព័ត៌មាន ឬរបាយការណ៍អំពីលទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមក្រុមប្រើប្រាស់គ្រឿងញៀនតាមរយៈគេហទំព័ររបស់ NCHADS ។

## ៤.២. ភារកិច្ចទទួលខុសត្រូវរបស់ KHANA រួមមាន ៖

៤.២.១. រៀបចំ និងពង្រឹងរចនាសម្ព័ន្ធរបស់បណ្តាញក្រុមប្រើប្រាស់គ្រឿងញៀន ដោយអនុវត្តតាមនិយាមបែបបទនៃយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ-ថែទាំ និងព្យាបាលបន្តជំងឺអេដស៍ (Boosted CoPCT among MARP) ឆ្នាំ២០១៣។

៤.២.២. ធានាថាអ្នកអប់រំផ្ទាល់ (Outreach Worker) បានផ្តល់ការអប់រំអំពីជំងឺអេដស៍ និងវិធានការបង្ការព្រមទាំងផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ពីរដងក្នុងមួយឆ្នាំអោយសំរេចបាន៖

- លើសពី៩០ភាគរយនៃ PWID ដែលមានប្រមាណចំនួន៨០០នាក់នៅរាជធានីភ្នំពេញ ចាប់ពីឆ្នាំ២០១៣ ទៅ ៖

1. ៥៦នាក់ នៅច្បារអំពៅ
2. ១៥ នាក់ ចាក់អង្រែ
3. ៥១នាក់ នៅបឹងត្របែក
4. ១៥នាក់ នៅបឹងទំពុន
5. ២៥នាក់ នៅស្តាតអូរឡាំពិក
6. ៤៦នាក់ នៅផ្សារតាប៉ាង
7. ៤៨នាក់ ផ្សារស៊ីឡឹប
8. ៣៥នាក់ នៅស្រះចក
9. ៣១នាក់ នៅបឹងឈូក
10. ៤៥នាក់ នៅភូមិថ្កោរ
11. ១៦នាក់ នៅស្ទឹងមានជ័យ
12. ១៧នាក់ នៅដង្កោ

- លើសពី៩០ភាគរយនៃ PWUD ចំនួនប្រមាណ ២,៧០០នាក់ ដែលមាននៅតាមបណ្តាទីតាំងសំខាន់ៗក្នុងរាជធានី និងខេត្ត ដូចខាងក្រោម ៖
  1. ៤៣២នាក់នៅខណ្ឌមានជ័យ(រាជធានីភ្នំពេញ)
  2. ១៧៩នាក់ នៅខណ្ឌចំការមន (រាជធានីភ្នំពេញ)
  3. ២០១នាក់ នៅខណ្ឌដូនពេញ (រាជធានីភ្នំពេញ)
  4. ២៥៣នាក់ នៅខណ្ឌទួលគោក (រាជធានីភ្នំពេញ)
  5. ១០២នាក់នៅខណ្ឌឫស្សីកែវ(រាជធានីភ្នំពេញ)
  6. ៧២នាក់នៅខណ្ឌដង្កោ (រាជធានីភ្នំពេញ)
  7. ៥៩២នាក់តាមរយៈអង្គការ SCC (ខេត្ត និងក្រុង សៀមរាប)
  8. ៣២៨នាក់តាមរយៈអង្គការ KBA និង SEADO (បឹងត្រកួន និងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)
  9. ២៦៥នាក់ តាមរយៈអង្គការOEC (ខេត្ត និងក្រុង បាត់ដំបង)
  10. ១៨០នាក់តាមរយៈអង្គការBWAP (ខេត្ត និងក្រុង ប៉ៃលិន)
  11. ១០០នាក់តាមរយៈអង្គការBSDA (ខេត្ត និងក្រុង កំពង់ចាម)

**៤.២.៣.** ចូលរួមរៀបចំ និងចងក្រងត្រួតពិនិត្យ ឬពិនិត្យឡើងវិញគោលនយោបាយ យុទ្ធវិធី វិធីសាស្ត្រ សេចក្តីណែនាំ និយាមបែបបទផ្សេងៗ ដែលពាក់ព័ន្ធនឹងការបង្ការការថែទាំ និងព្យាបាលបន្តជំងឺអេដស៍ចំពោះ MARP។

**៤.២.៤.** បង្កើនសមត្ថភាពបុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលជាអ្នកអភិបាលផ្ទាល់លើអ្នកអប់រំផ្ទាល់ (Outreach Worker) នៃការងារបង្ការ-ថែទាំ និងព្យាបាលបន្តជំងឺអេដស៍។

**៤.២.៥.** ចូលរួមជាមួយ NCHADS និងដៃគូពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍន៍បណ្តុះបណ្តាលអ្នកអប់រំផ្ទាល់ (Outreach Worker) អំពីការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍។

**៤.២.៦.** ធានាថា PWID និង PWUD ទាំងអស់ (១០០ភាគរយ) ដែលមានលទ្ធផលតេស្តរកមេរោគអេដស៍វិជ្ជមាននឹងទទួលបានភ្លាមៗ ឬដោយឆាប់រហ័សការព្យាបាលដោយឱសថ ARV និងសេវាពាក់ព័ន្ធនានាផ្សេងទៀត ដោយសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ (NCHADS), កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត (PASP) និងសេវាថែទាំ និងព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ (Pre ART/ART)។

**៤.២.៧.** ពិនិត្យតាមដាន និងផ្តល់សេវាគាំទ្រសមស្របនានានៅតាមសហគមន៍មូលដ្ឋានដល់អ្នកប្រើប្រាស់គ្រឿងមានផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍។

**៤.២.៨.** ផ្សព្វផ្សាយព័ត៌មាន ក៏ដូចជារបាយការណ៍អំពីលទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍នៅក្នុងចំណោមក្រុមប្រើប្រាស់គ្រឿងញៀនតាមរយៈគេហទំព័រ ឬព្រឹត្តប័ត្រព័ត៌មានរបស់ KHANA។

រាជធានីភ្នំពេញ, ថ្ងៃទី...៥...ខែ...[illegible]...ឆ្នាំ២០១៣

**នាយកប្រតិបត្តិអង្គការខាណា**

ខាណា KHANA

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ**

វេជ្ជ. មាន ឈីវុន

ចំលងជូន:
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសុខាភិបាល
- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- នាយកដ្ឋានការពារសុខភាព
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
- ឯកសារ